**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួល និងបំពេញបន្ថែមមាត្រា ៥ ចំណុច ៥.១ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ /នស / រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានកែសម្រួល និងបំពេញបន្ថែមមាត្រា ៥ ចំណុច ៥.១ ស្តីពីសមាសភាពក្រុមប្រឹក្សាភិបាល វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដូចតទៅ :

មាត្រា ៥ ចំណុច ៥.១. ថ្មី :

ក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមានសមាជិក ៧ ( ប្រាំពីរ ) រូប ដែលមានសមាសភាព ដូចតទៅ :

| | |
|---|---|
| - អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ | ប្រធាន |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | សមាជិកស្ម័យប្រវត្តិ |
| - តំណាងអ្នកដាំកៅស៊ូ | សមាជិក |
| - តំណាងបុគ្គលិកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | សមាជិកស្ម័យប្រវត្តិ |

**មាត្រា ២ :** ក្រៅពីការកែសម្រួល និងបំពេញបន្ថែមខាងលើ ខ្លឹមសារដែលមានចែងក្នុងអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវ កៅស៊ូកម្ពុជាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅជាធរមានដដែល ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ